**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: [illegible]....សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

## ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តាការិយាល័យនៃ នាយកដ្ឋានរដ្ឋាករ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

*** ✿✿✿ ***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តាការិយាល័យនៃនាយកដ្ឋានរដ្ឋាករ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងកំណត់នូវមុខងារ និងភារកិច្ចរបស់បណ្តាការិយាល័យទាំងនេះ។

**ប្រការ ២.-**

ត្រូវបានកំណត់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានរដ្ឋាករ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នូវការិយាល័យចំនួន បី (០៣) ដូចខាងក្រោម :

① - ការិយាល័យគោលនយោបាយរដ្ឋាករ និងគ្រប់គ្រង

② - ការិយាល័យគ្រប់គ្រងផលិតផលប្រេងសិលា និងថាមពល

③ - ការិយាល័យបង្ការ បង្ក្រាបបទល្មើស និងគ្រប់គ្រងផលិតកម្ម

បណ្តាការិយាល័យនីមួយៗរបស់នាយកដ្ឋានរដ្ឋាករ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ដែលទទួលខុសត្រូវតាមភារកិច្ច ដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាកំណត់។

**ប្រការ ៣.-**

ការិយាល័យគោលនយោបាយរដ្ឋាករ និងគ្រប់គ្រង មានមុខងារ និងភារកិច្ចដូចតទៅ :

- លើកឡើងនូវសំណើគោលនយោបាយ ពាក់ព័ន្ធនឹង ពន្ធអាករ ការគ្រប់គ្រងផលិតកម្ម ការនាំចេញនាំចូល ការធ្វើពាណិជ្ជកម្មចែកចាយ ការធ្វើសន្និធិផលិតផលប្រេងសិលា និងផលិតផលជាប់អាករពិសេសផ្សេងទៀត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- កសាងនូវផែនការមេ និងផែនការសកម្មភាពសំរាប់អភិវឌ្ឍន៍វិស័យរដ្ឋាករ និងសំរាប់កិច្ចសម្រួលពាណិជ្ជកម្មតាមរបបគយនីមួយៗរបស់អង្គភាពគយ និងរដ្ឋាករ ។
- គ្រប់គ្រងកិច្ចដំណើរការរបស់អាគារលក់ទំនិញរួចពន្ធនៅទូទាំងប្រទេស ។
- ទទួលបន្ទុកការងារគ្រប់គ្រងរដ្ឋបាល ស្ថិតិ និងគណនេយ្យរបស់នាយកដ្ឋានរដ្ឋាករ ។
- គ្រប់គ្រងការចេញលិខិតអនុញ្ញាតនាំចេញ- នាំចូល និងប័ណ្ណសំគាល់មធ្យោបាយដឹកជញ្ជូនផលិតផលប្រេងសិលាគ្រប់ប្រភេទ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានរដ្ឋាករ ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្រ្តីរាជការក្រោមឱវាទ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

**ប្រការ ៤.-**

ការិយាល័យគ្រប់គ្រងផលិតផលប្រេងសិលា និងថាមពល មានមុខងារ និងភារកិច្ចដូចតទៅ :

- គ្រប់គ្រង ត្រួតពិនិត្យបែបបទគយនាំចេញ- នាំចូល លើផលិតផលប្រេងសិលា និងថាមពល តាមបទបញ្ញត្តិច្បាប់ជាធរមាន។
- គ្រប់គ្រង ត្រួតពិនិត្យ វាស់វែង តាមដានការដឹកជញ្ជូន ចរាចរចែកចាយ ការបញ្ចេញបញ្ចូល ជាពិសេសទទួលបន្ទុកគ្រប់គ្រងការចេញលិខិតអនុញ្ញាតដឹកជញ្ជូនផលិតផលប្រេងសិលា នៅតាមមណ្ឌលឃ្លាំង ឬអាជីវកម្មដ្ឋាននានានៅទូទាំងប្រទេស តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

**ប្រការ ៥.-**

ការិយាល័យបង្ការ បង្ក្រាបបទល្មើស និងគ្រប់គ្រងផលិតកម្ម មានមុខងារ និងភារកិច្ចដូចតទៅ :

- សហការជាមួយអង្គភាពគយនិងរដ្ឋាករ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត កសាងគោលនយោបាយបំពីនិងការស្រាវជ្រាវ បង្ការ និងបង្ក្រាបបទល្មើសពាក់ព័ន្ធនឹងអាជីវកម្មផលិតផលគេលសិលា និងថាមពល។
- ចាត់វិធានការស្រាវជ្រាវ បង្ការ និងបង្ក្រាបអំពើល្មើសពាក់ព័ន្ធនឹងអាជីវកម្មផលិតផលគេលសិលា នៅទូទាំងដែនគយ នៃព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមបទបញ្ញត្តិច្បាប់ជាធរមាន និងតាមបទបញ្ជារបស់អគ្គនាយកគយ និងរដ្ឋាករកម្ពុជា។
- សហការជាមួយអង្គភាពគយនិងរដ្ឋាករ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីប្រមូល ផ្លាស់ប្តូរ និងបញ្ជូនព័ត៌មានពាក់ព័ន្ធនឹងសកម្មភាពមិនប្រក្រតីនានាលើបុគ្គល មធ្យោបាយដឹកជញ្ជូន និងល្បិចល្មើសគ្រប់ប្រភេទលើមុខទំនិញផលិតផលគេលសិលា និងថាមពល។
- គ្រប់គ្រង និងត្រួតពិនិត្យកិច្ចដំណើរការផលិតកម្មក្នុងស្រុកនូវផលិតផលគេលសិលា ជីវឥន្ធនៈ និងផលិតផលជាប់អាករពិសេសផ្សេងទៀត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៦.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាកាដជាតិ
- គ្រប់សាលាខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ